ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ០៤៥/១៦ ក.ជ.ប.ក

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែកុម្ភៈ និងទិសដៅខែ មីនា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

អំពើជួញដូរមនុស្សជាបទឧក្រិដ្ឋធ្ងន់ធ្ងរ គឺជាបញ្ហាសកលដែលកំពុងតែជះឥទ្ធិពលលើ ប្រទេសកំពុងអភិវឌ្ឍ រួមទាំងប្រទេសកម្ពុជាផងដែរ ដោយសារមានកំណើននៃប្រជាជននៅលើសកលលោក ជាកត្តាឲ្យមានកង្វះការងារធ្វើ រួមផ្សំនឹងប្រទេសខ្លះមានសង្គ្រាមផ្ទៃក្នុងផង បាតុភូតជាប្រវត្តិសាស្ត្រនេះ បានតម្រូវឲ្យមានការផ្លាស់ប្តូរការធ្វើទេសន្តរប្រវេសន៍ឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយទៀត បានផ្តល់ឱកាសឲ្យមានបទល្មើសអំពើជួញដូរមនុស្សគ្រប់រូបភាពទាំងស្របច្បាប់ និងមិនស្របច្បាប់ មានការវិវឌ្ឍនអាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ច នយោបាយ និងបរិយាកាសសង្គម ដែលជាហេតុទាមទារឲ្យមានការរួបរួមគ្នាប្រយុទ្ធប្រឆាំងបង្ការទប់ស្កាត់អំពើជួញដូរមនុស្សឲ្យបានទាន់ពេលវេលា ។

សេចក្តីត្រូវការផ្នែកសម្ភារ និងស្មារតី របស់មនុស្សកំពុងអភិវឌ្ឍ ដើម្បីជីវភាពគ្រួសារមួយ ពួកគេរិះរកគ្រប់មធ្យោបាយ ទោះបីឆ្លងកាត់ឧបសគ្គ និងហានិភ័យទាំងឡាយ ក៏ពួកគេនៅតែជម្នះធ្វើយ៉ាងណា ដើម្បីសម្រេចតាម គោលបំណងរបស់ ខ្លួន អ្នកខ្លះមានមហិច្ឆតាខ្ពស់ រហូតបង្កើតគំនិតប្រាស់ចាកពីច្បាប់នៅក្នុងសង្គមមនុស្ស បង្កភាពស្មុគស្មាញដល់គ្រួសារ ដល់អ្នកដទៃ ដល់ប្រទេសជាតិ និងនៅជុំវិញពិភពលោក បង្កើតជាបទល្មើសផ្សេងៗ ជាពិសេសអំពើជួញដូរមនុស្ស ហើយពួកជនទាំងនោះធ្វើសកម្មភាពបោកបញ្ឆោតលើជនទន់ខ្សោយ អវិជ្ជា ក្រីក្រ អូសទាញតាមរូប ភាពផ្សេងៗ តាមរយៈរកការងារ ឲ្យធ្វើនៅក្នុងប្រទេស និងក្រៅប្រទេស(ផ្នែកកសិកម្ម ,ឧស្សាហកម្ម ,នេសាទ សមុទ្រ និងស្ត្រីបម្រើតាមផ្ទះ) មានប្រទេសថៃ ម៉ាឡេស៊ី ,ឥណ្ឌូនេស៊ី ។ល។ និងស្ត្រីពេញវ័យត្រូវបានមេខ្យល់បោកប្រាស់ តាមរយៈរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស (ជនជាតិចិន កូរ៉េ និងប្រទេសមួយចំនួនទៀត) ដែលពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

ប្រជាពលរដ្ឋរងគ្រោះទាំងនោះ ជាពិសេស បុរស ស្ត្រីនិងកុមារ ក្រោយពីបានដឹងថាចាញ់បោកគេដោយអំពើជួញដូរមនុស្ស ពួកគាត់ត្រូវស្វែងរកជំនួយអន្តរាគមន៍ពីអាជ្ញាធរ និងសមត្ថកិច្ចនៅក្នុងប្រទេស និងក្រៅប្រទេសជាបន្តបន្ទាប់ ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញ តួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តគ្រប់វិធី និងដឹកនាំជាយុទ្ធសាស្ត្រ តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តជំរុញសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និង លិខិតបទដ្ឋាន គតិយុត្ត ការងារដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្មលើជនល្មើស ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានាសុំឲ្យមានកិច្ចសហការស្រាវជ្រាវនូវបទល្មើស និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។

របាយការណ៍ខាងក្រោមជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២៣ច្បាប់ គឺខេត្ត(រាជធានីភ្នំពេញ ,កោះកុង ,ព្រះសីហនុ ,កំពត ,កែប ,តាកែវ ,កណ្តាល ,ស្វាយរៀង ,កំពង់ឆ្នាំង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង ,បន្ទាយមានជ័យ , ឧត្តរមានជ័យ ,ព្រះវិហារ ,សៀមរាម ,កំពង់ធំ , ត្បូងឃ្មុំ ,កំពង់ចាម ,ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី) និងសកម្មភាព របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

#### ១. ការងារបង្ការ-ទប់ស្កាត់:

#### ១.១.ការផ្សព្វផ្សាយ អប់រំ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ចបានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន៦៥០លើក បើប្រៀបធៀបខែមុនមានចំនួន១,២៣៧លើក មានការថយចុះចំនួន៥៨៧លើក ស្មើនឹង៤៧,៤៥% និងមានមនុស្សចូលរួមសរុបចំនួន **៧៩,០៦២** នាក់ បើប្រៀបធៀបខែមុនមានចំនួន**១៥៤,៨៤៤**នាក់ មានការថយចុះចំនួន**៧៥,៧៨២**នាក់ ស្មើនឹង៤៨,៩៤% ក្នុងនោះស្ត្រីមានចំនួន៤០,៣៨៨នាក់។ **(ឧបសម្ព័ន្ធទី១)**

#### ១.២.ការងារបង្ការ-ទប់ស្កាត់

- យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចកងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ ទទួលបានលទ្ធផលសរុបចំនួន ៦៨១លើក បើប្រៀបធៀបខែមុនមានចំនួន៥៦២លើក មានការកើនឡើង១១៩លើក ស្មើនឹង២១,១៧% មានមនុស្សចំនួន២,៣១១នាក់ បើប្រៀបធៀបខែមុនមានចំនួន៣,៩៥២នាក់ មានការថយចុះចំនួន១,៦៤១លើក ស្មើនឹង **៤១,៥២%** ក្នុងនោះ ស្ត្រី ចំនួន **១,៣៥៤** នាក់ ។**(ឧបសម្ព័ន្ធទី២)**

○ ស្នងការដ្ឋាននគរបាលខេត្ត កណ្ដាល, ឧត្តរមានជ័យ,ខេត្តតាកែវ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តអំពើសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ កម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា,ខារ៉ាអូខេ បានចំនួន១៤៦គោលដៅ និងមានមនុស្សចំនួន ៥៥៤នាក់ (ស្រីចំនួន៤៩៤នាក់)ចូលរួមស្តាប់ ។

- ស្នងការដ្ឋាននគរបាលខេត្ត បានចាត់កម្លាំងជំនាញចុះល្បាត និងក្តាប់សភាពការណ៍តាមគោលដៅសង្ស័យខារ៉ាអូខេ ម៉ាស្សា និងក្លឹបកម្សាន្ត ចំនួន១៤ គោលដៅ មានចំនួនសរុប១៥០នាក់ ស្រីចំនួន១២៦នាក់ ។

○ បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្ត មានចំនួន៧១គោលដៅក្នុងនោះអំពើជួញដូរមនុស្សចំនួន០៥ គោលដៅនិងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ ។

○ ស្នងការដ្ឋាននគរបាលខេត្ត **មណ្ឌលគិរី** បានចុះត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារចំនួន០៥កន្លែងស្មើនឹង០៥គោលដៅ នៅក្នុងក្រុងសែនមនោរម្យ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**៧៣**នាក់ ស្រីចំនួន**៣៧**នាក់ ។

○ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត**បាត់ដំបង** បានចូលរួមធ្វើវាគ្មិននៅវិទ្យុជាតិចម្ការចេក FM៩២.៧0MHz ក្នុងកម្មវិធី សន្ទនាមតិពន្លឺមូលដ្ឋាន ក្រោមប្រធានបទ ស្តីពី *ជំរុញដល់ក្រុមហ៊ុនឯកជន ដើម្បីពង្រឹងបទបញ្ញត្តិការពារពលករ*

○ គណៈបញ្ជាការសាលាក្រុងសៀមរាប បានចុះចលនា និងត្រួតពិនិត្យប្រជាការពារនៅតាមបណ្តាប៉ុស្តិ៍សរុបចំនួន ១៤១គោលដៅ មានកម្លាំងរួមចំនួន២៥៣២នាក់ លើភូមិចំនួន១០៨ ដោយធ្វើការត្រួតពិនិត្យជាប្រចាំ ។

-ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនិងអំពើជួញដូរមនុស្ស តាមវិទ្យុបានចំនួន០៤លើក និងល្បាតពេលយប់នៅតាមផ្សាររាត្រី តាមមាត់ស្ទឹង និតាមសួនច្បារមុខមហាអង្គរ សណ្ឋាគារ(Grand Hotel) ។

○ ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តកែប បានចុះល្បាតត្រួតពិនិត្យនៅតាមបណ្តាគោលដៅ ខារ៉ាអូខេ ម៉ាស្សា និងក្លឹបកម្សាន្ត ទូទាំងខេត្ត ១៤គោលដៅ មានមនុស្សចំនួន ១៥០នាក់ ស្រីចំនួន១២៦នាក់

**២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍**

**២.១ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ**

-គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)បានសហការជាមួយ អង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកំលាំងពលកម្ម សរុបបានចំនួន១៥៣នាក់ បើប្រៀបធៀបខែមុនមានចំនួន៣១នាក់ មានការកើនឡើងចំនួន ១២២នាក់ ស្មើនឹង៣៩៣,៥៤% ក្នុងនោះស្ត្រី មានចំនួន១២៦នាក់។ ( **ឧបសម្ព័ន្ធទី៣**)

**២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍: ក្នុងខែកុម្ភៈ ឆ្នាំ ២០១៦ ( គ្មាន )**

**២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេស:**

-ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ បញ្ជូនមកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត មានចំនួន៣,៣៣៩នាក់(ស្រីចំនួន១,០៨៤នាក់) អនីតិជនចំនួន២៣៥នាក់ (ស្រីចំនួន១០៥នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន៤១នាក់ ត្រូវអាជ្ញាធរថៃ ឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ។ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

**៣. ការងារអនុវត្តច្បាប់**

-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស

នាយកដ្ឋានជំនាញនិងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេសខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៩ករណី/០៣ករណី(បើប្រៀបធៀបខែមុនកើនឡើង០៦ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន១១នាក់ (ស្រីចំនួន០៧នាក់) សង្គ្រោះជនរងគ្រោះបានចំនួន១៥នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០៤នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១១នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៦នាក់ និងចំនួន០៩នាក់ទៀត ប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

➢ **អំពើជួញដូរមនុស្ស**

សរុបចំនួន០៣ករណី/០ករណី ជនសង្ស័យចំនួន០៥នាក់(ស្រី០៤នាក់) ជនរងគ្រោះចំនួន០៥នាក់ អាយុ១៨ឆ្នាំឡើងចំនួន០៥នាក់ (ប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

-ការនាំយកចេញដោយមិនស្របច្បាប់មានគោលដៅ ០៣ករណី ជនសង្ស័យ ០៥នាក់

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ:**

សរុបចំនួន០៦ករណី/០៣ករណី ជនសង្ស័យចំនួន០៦នាក់(ស្រី០៣នាក់)ជនរងគ្រោះចំនួន១០នាក់ អាយុក្រោម១៥ឆ្នាំចំនួន០៤នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន០៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៦នាក់ និងចំនួន០៤នាក់ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

-សញ្ញារកម្ម ០២ករណី ជនសង្ស័យ ០២នាក់

-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ០៣ករណី ជនសង្ស័យ ០៣នាក់

-អំពើអាសប្រាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ០១ករណី ជនសង្ស័យ ០១នាក់

**៤. ការងារកិច្ចការយុត្តិធម៌** កំពុងប្រមូលទិន្នន័យពីសាលាដំបូងរាជធានី/ខេត្ត និងស្រង់តួលេខ នៅដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជម្រះ ។

**៥. ការងារសហប្រតិបត្តិការអន្តរជាតិ**

+**ក្រុមការងារអនុវត្តន៍ច្បាប់** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ចំនួន០២រូប បានចូលរួមកិច្ចប្រជុំនៅក្នុងប្រទេសថៃ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅតំបន់អាស៊ីអាគ្នេយ៍ និងក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការស៊ើបអង្កេតលើករណីកេងប្រវ័ញ្ចផ្លូវភេទ ដូចជា ការធ្វើពេស្យាកម្ម ការថតរូបភាពវីដេអូ និងការជួញដូរមនុស្ស (នៅប្រទេសជប៉ុន ) ។

+**ខេត្តព្រះវិហារ** ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមកិច្ចប្រជុំជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងឡាវ ចំនួន០១លើក ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលកើតមានឡើងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ឆ្លងដែនខុសច្បាប់ ។

+**ខេត្ត ប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុនចំនួន ០២ ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន០២លើក មានពលករចំនួន៨៨នាក់ ស្រីចំនួន៤២នាក់។

**៦. ការងារពាក់ព័ន្ធនឹងកុមារ**

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម របស់គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន០២នាក់ ក្នុងនោះជាកុមារីចំនួន០២នាក់

+មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ បានទទួលកុមាររងគ្រោះដោយអំពើជួញដូរមនុស្សឲ្យស្នាក់នៅរយៈពេលខ្លីនៅមណ្ឌលស្តារនីតិសម្បទាមានចំនួន០២នាក់ និងកុមារីចំនួន០២នាក់ ។

- មានមណ្ឌលរដ្ឋ និងមណ្ឌលអង្គការនានាបានទទួលកុមារឲ្យស្នាក់នៅ និងបានទទួលនូវការបណ្តុះបណ្តាវិជ្ជាជីវៈ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង បានផ្តល់សេវាចិញ្ចឹមកុមារនៅមណ្ឌលបុរីកុមារកំព្រាទី១ និងមណ្ឌលបុរីកុមារកំព្រាទី២ខេត្ត ដោយមានការឧបត្ថម្ភគាំទ្រថវិការបស់រាជរដ្ឋាភិបាល អង្គការ ASPECA ប្រចាំនៅកម្ពុជា និងអង្គការ CIFA ដែលមានកុមារសរុបចំនួន២៤១នាក់ កុមារីចំនួន១០៥នាក់ ។

+មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តពោធិ៍សាត់ បានទទួលកុមារស្នាក់នៅមានចំនួន២៦១នាក់ និងកុមារីចំនួន១២៦នាក់ ក្នុងនោះ(មណ្ឌលរដ្ឋ១ មានកុមារស្នាក់នៅសរុបចំនួន៤៧នាក់ កុមារីចនួន២៥នាក់ មណ្ឌលអង្គការផ្សេងៗចំនួន៥ មាន កុមារស្នាក់នៅសរុបចំនួន១៣៦នាក់ កុមារីចំនួន៦០នាក់ និងមណ្ឌលអង្គការក្នុងសហគមន៍មានកុមារស្នាក់សរុបចំនួន៧៨នាក់ កុមារីចំនួន៤១នាក់)កុមារទាំងនេះបានទទួលនូវការបណ្តុះបណ្តុះលវិជ្ជាជីវៈ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំង បានទទួលកុមារស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងមណ្ឌលអង្គការចំនួន១១កន្លែង ដែលមានកុមារសរុបចំនួន២៧៥នាក់ កុមារីចំនួន៩៥នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំង បានទទួលកុមារស្នាក់នៅក្នុងមណ្ឌលមានចំនួន ៦៨នាក់ កុមារីចំនួន៣១នាក់ ក្នុងនោះមានមណ្ឌលអង្គការ EAA បានទទួលកុមារស្នាក់នៅចំនួន២៦នាក់ និងមណ្ឌលអង្គការ ESK បានទទួលកុមារស្នាក់នៅចំនួន១០ នាក់ ស្រីចំនួន០៧នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រចេះ បានសហការជាមួយអង្គការភូមិកុមារកម្ពុជា SOS ប្រចាំខេត្តក្រចេះ បានទទួលកុមារស្នាក់នៅក្នុងមណ្ឌលអង្គការនេះមានចំនួន១០៨ កុមារីចំនួន៤៥នាក់ និងបានផ្តល់អហាររូបត្ថម្ភដល់កុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ចំនួន៣០០នាក់ ស្រីចំនួន១៥០នាក់ ។

**៧. ការងារទេសន្តរប្រវេសន៍**

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន១១៤គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន១៥នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការិនីរង គ្រោះចំនួន០៩នាក់ ក្នុងនោះមាន ៖

-មកពីប្រទេសម៉ាឡេស៊ី ចំនួន០៣នាក់ ទៅដោយខ្លួនឯង ។

-មកពីប្រទេសចិនចំនួន០៦នាក់ ទៅតាមការសម្ភាស តាមរយៈមេខ្យល់ ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**ខេត្តបាត់ដំបង** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន៥៣,២៦៤នាក់(ស្រីចំនួន២៣,២៤៤នាក់) អនីតិជន មានចំនួន១,១១២នាក់ (ស្រីចំនួន៧២៤នាក់ ) ក្នុងនោះស្របច្បាប់ ចំនួន២០,៩៦២នាក់ (ស្រីចំនួន៩,៥៦១នាក់) និងអនីតិជនចំនួន១៤៧នាក់ (ស្រីចំនួន១៣៦នាក់) មិនស្របច្បាប់ចំនួន៣២,៣០២ នាក់ (ស្រីចំនួន ១៤,១៨៣នាក់) និងអនីតិជនចំនួន៩៦៥នាក់ ( ស្រីចំនួន៥៨៨នាក់ ) ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**ខេត្តបន្ទាយមានជ័យ** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន៦,៣៤៧នាក់(ស្រីចំនួន២,៩៩៨នាក់) អនីតិជន មានចំនួន៩៧នាក់ ក្នុងនោះស្របច្បាប់ ចំនួន៣៤៨នាក់ (ស្រីចំនួន១៦៣នាក់) មិនស្របច្បាប់ចំនួន៥,៩៩៩ នាក់ (ស្រីចំនួន ២,៨៣៥នាក់) និងអនីតិជនចំនួន៩៧នាក់ ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**ខេត្តស្វាយរៀង** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន១១,២៤៩នាក់(ស្រីចំនួន៤,៤១០នាក់) អនីតិជនមានចំនួន១៦៦នាក់ (ស្រីចំនួន៦០នាក់ ) ក្នុងនោះស្របច្បាប់ ចំនួន៧,២៧៣នាក់ (ស្រីចំនួន២,៨៥៨នាក់) មិនស្របច្បាប់ចំនួន៣,៩៧៦ នាក់ (ស្រីចំនួន ១,៥៥២នាក់) ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន**ខេត្តពោធិ៍សាត់** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន៥២,២១៣នាក់(ស្រីចំនួន២៣,៨២៤នាក់) អនីតិជនមានចំនួន៦៨៩នាក់ (ស្រីចំនួន២៧៨នាក់ ) ក្នុងនោះស្របច្បាប់ ចំនួន២៤,៤៩១នាក់ (ស្រីចំនួន១២,៨១៥នាក់) អនីតិជនមានចំនួន១៤៣នាក់ (ស្រីចំនួន៨៣នាក់ ) មិនស្របច្បាប់ចំនួន២៧,៧២២ នាក់ (ស្រីចំនួន ១១,០០៩នាក់) អនីតិជនមានចំនួន៥៤៦នាក់ (ស្រីចំនួន១៩៥នាក់ )។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន**ខេត្តសៀមរាប** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន២,៣៤៦នាក់(ស្រីចំនួន៧៥៨នាក់) អនីតិជនមានចំនួន១៩នាក់ (ស្រីចំនួន០៧នាក់ ) ក្នុងនោះស្របច្បាប់ ចំនួន១,២២៣នាក់ (ស្រីចំនួន៤២០នាក់) អនីតិជនមានចំនួន០៨នាក់ (ស្រីចំនួន០៣នាក់ ) មិនស្របច្បាប់ចំនួន១១០ នាក់ (ស្រីចំនួន ៣៣នាក់) អនីតិជនមានចំនួន០៦នាក់ (ស្រីចំនួន០៣នាក់ )។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន**ខេត្តកែប** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន០៣នាក់(ស្រីចំនួន០១នាក់) ក្នុងនោះស្របច្បាប់ចំនួន០២នាក់(ប្រុស) មិនស្របច្បាប់០១នាក់(ស្រី) ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន**ខេត្តព្រះស៊ីហនុ** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន៤២នាក់(ស្រីចំនួន១៥នាក់) អនីតិជនមានចំនួន០១នាក់ ក្នុងនោះស្របច្បាប់ ចំនួន១៧នាក់ (ស្រីចំនួន០៤នាក់) អនីតិជនមានចំនួន0នាក់ មិនស្របច្បាប់ចំនួន២៥នាក់ (ស្រីចំនួន ១១នាក់) ។

- បានវិលត្រឡប់មកស្រុកកំណើតវិញចំនួន១២នាក់ ស្រីចំនួន០៧នាក់ ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនខេត្តកំពង់ធំ ពលករទេសន្តរប្រវេសន៍ ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន**២២៤**នាក់(ស្រីចំនួន**៦៤**នាក់) ក្នុងនោះស្របច្បាប់ ចំនួន**៥០**នាក់ (ស្រីចំនួន**៣០**នាក់) មិនស្របច្បាប់ចំនួន**១៣៤**នាក់ (ស្រីចំនួន **៣៤**នាក់) ។

○ តាមទិន្នន័យរបស់ស្នងការដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន**ខេត្តកំពង់ឆ្នាំង** ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែកុម្ភៈ ឆ្នាំ២០១៦ សរុបបានចំនួន**៧,៣៧៥**នាក់(ស្រីចំនួន **២,៦៩៥**នាក់ ក្នុងនោះស្របច្បាប់ ចំនួន**៤,៤៤២**នាក់ (ស្រីចំនួន**១,៩២៩**នាក់) មិនស្របច្បាប់ចំនួន**២,៩៣៣** នាក់ (ស្រីចំនួន **៧៦៦**នាក់) អនីតិជនមានចំនួន**៣០**នាក់ (ស្រីចំនួន**០៨**នាក់ )។

- បានវិលត្រឡប់មកស្រុកកំណើតវិញចំនួន៨៧០នាក់ ស្រីចំនួន១៩៥នាក់ ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន**៦៦**លើក ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និង គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

### +សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

-បានអញ្ជើញជាអធិបតីភាព ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០១៥ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តព្រះវិហារ នាររសៀលថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានអញ្ជើញជាអធិបតីភាព ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០១៥ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង នាររសៀលថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយតំណាងមកពី អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ស្តីពីការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរជាមួយ ជនបរទេស(ពិសេសចិន) ដើម្បីកែលម្អចំណុចខ្វះខាតក្នុងដំណើរការច្រកចេញចូលតែមួយ នៅសាល ប្រជុំ គ.ជ.ប.ជ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិនិត្យរបាយការណ៍ឆ្នាំតាមក្រុមជំនួយកិច្ចការទាំង៦ របស់អគ្គលេខាធិការដ្ឋានឡើងវិញ ដោយធ្វើការកែតម្រូវ និងផ្ទៀងផ្ទាត់ទិន្នន័យនៃលទ្ធផលត្រឹមត្រូវដែល ប្រមូលបានពី ស្ថាប័នជំនាញដែលពាក់ព័ន្ធក្រុមនីមួយៗ ជាលើកចុងក្រោយ ដើម្បីបូកសរុបដាក់បញ្ចូលក្នុងរបាយការណ៍ឆ្នាំ របស់ គ.ជ.ប.ជ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានជួបប្រជុំពិភាក្សាដកស្រង់បទពិសោធន៍ការងារប្រឆាំងអំពើជួញដូរមនុស្ស រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាមួយគណៈប្រតិភូជាន់ខ្ពស់ ប្រទេសនេប៉ាល់ ដែលដឹកនាំដោយ លោកជំទាវ Radhika Aryal រដ្ឋលេខាធិការក្រសួងស្ត្រី កុមារ និងសុខុមាលភាពសង្គម ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីកិច្ចព្រមព្រៀង និងផែនការសកម្មភាព កម្ពុជា-ចិន អំពីការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរជាមួយចិន នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានអញ្ជើញជាអធិបតីភាព ក្នុងពីធីផ្សព្វផ្សាយគោលនយោបាយអប់រំ កំណែទម្រង់វិស័យអប់រំ និងគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា នៅវិទ្យាល័យ ព្រះបាទសុរាម្រឹត ក្រុងកំពង់ឆ្នាំង និងនៅវិទ្យាល័យសីហមុនី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្តីពី ថវិកាឆ្លើយតបនឹងយេនឌ័រ ដែលមានសមាសភាពមកពីគ្រប់បណ្តាក្រសួង-ស្ថាប័នចំនួន ១៨២នាក់ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ព្រឹក ។

-បានអញ្ជើញធ្វើជាវាគ្មិនពិសេសក្នុងវេទិកាអ្នកស្តាប់វិទ្យុអាស៊ីសេរី ពិភាក្សាលើប្រធានបទ យន្តការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានជួបពិភាក្សាជាមួយអ្នកតាមដានខាងក្រៅ លោក Adam Novak មកពី សហគមន៍អឺរ៉ុប ស្តីពីការងារទេសន្តរប្រវេសន៍ និងគម្រោងMIGRA-SAFE នៅសាលVIPក្រសួងមហាផ្ទៃ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានអញ្ជើញជាគណៈអធិបតីក្នុង សន្និបាតបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ របស់គ.ជ.ប.ជ និងពិធីប្រកាសដាក់ឲ្យប្រើប្រាស់គោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ អគារទ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងជាមួយមន្ត្រីលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពង្រឹងសមត្ថភាពអនុវត្តការងារ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ។

+ក្រុមការងារអនុវត្តន៍ច្បាប់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន០៤រូប បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០១លើក ស្តីពីការស៊ើបអង្កេតមូលដ្ឋាន នៅសណ្ឋាគារសាន់វ៉េ ។

### ឃ. ការលើកកម្ពស់សមត្ថភាព

**១.ការបណ្តុះបណ្តាល (គ្មាន)**

**២. សិក្ខាសាលា ( គ្មាន )**

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែកុម្ភៈ ឆ្នាំ២០១៦ នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារដោយលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្តគ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋានគ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួមជាស្រេច។

២.បានដាក់ចុះផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)សម្រាប់រយៈ ពេល ៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារ ទាំង ៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

### ខ.ចំណុចសេសសល់ នឹងភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់បានឆ្លើយតបលទ្ធ ផលការងារ តាមរយៈរបាយការណ៍តាមការកំណត់ នៅឡើយ ។

- ត្រូវការពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តបន្តទៀត អាស្រ័យដោយមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឧកខានឆ្លើយតបទៅនឹងសភាពការណ៍បទល្មើសបាន។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតមទាន់សភាពការណ៍។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើតាម។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ព្រមទាំងចំណេះដឹងនិងការអប់រំ របស់ពួកគាត់មានកម្រិតទាបដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តហ៊ានហ៊ើសទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិការគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## IV.ទិសដៅសម្រាប់ខែមីនា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តប្រវេសន៍។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៣-២០១៨ ពាក់កណ្តាលអណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះទាំងតាម បណ្តាក្រសួងស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញអនុវត្ត។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៦. ធ្វើការស្រាវជ្រាវអំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែង យល់ពីកក្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នា ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល(ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌។

១០. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១២. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និង រវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រ ដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការក្រុម និងផែនការរាជធានី/ខេត្ត។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត។

១៤. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបាន ដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ០៣ ឆ្នាំ២០១៦
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក.**ចៅង_សំអាត**

**បានឃើញ និង ឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ០៣ ឆ្នាំ២០១៦
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**
-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ
"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"
-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារ អនុវត្តន៍ច្បាប់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ភូមិ-ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ។ | ស្នងការដ្ឋាននគរបាលខេត្តតាកែវ, ស្វាយរៀង និងកំពង់ | 303 លើក | 27,271 នាក់ | 14,483 នាក់ |
| 2 | កណ្តាល | បានធ្វើវេទិកាសាធារណៈ ស្តីអំពីការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស និងសកម្មភាព ភូមិ /ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 33 លើក | 9,389 នាក់ | 2,495 នាក់ |
| | | មន្ទីរអប់រំខេត្តបានធ្វើសកម្មភាពបញ្ជ្រាបការផ្សព្វផ្សាយ ការបង្ការការទប់ស្កាត់ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកំលាំងពលកម្ម និងផ្លូវភេទ លើស្រ្តីនិងកុមារ បស់លោកគ្រូអ្នកគ្រូ ប្រធាន អនុប្រធានការិយាល័យ អប់រំ យុវជននិងកីឡា ស្រុកក្រុងទូទាំងខេត្ត និងដល់សិស្សានុសិស្ស នៅតាមវិទ្យាល័យដូចជា វិទ្យាល័យ ហ៊ុន សែន សេរីភាព នុងស្រុកស្អាង កោះធំ កណ្តាលស្ទឹង ខ្សាច់កណ្តាល និងល្វាឯម | ក្រសួងអប់រំ | 33 លើក | 2,597 នាក់ | 1,457 នាក់ |
| 3 | ត្បូងឃ្មុំ | ផ្សព្វផ្សាយតាមរយៈវេទិការសារធារណៈ ស្តីពី សុវត្ថិភាពក្នុងនោះសង្កត់ធ្ងន់លើការចំណាក់ស្រុកដោយប្រថុយប្រថានដល់ប្រជាពលរដ្ឋ ស្រុកមេមត់ ស្រុកតំបែរ ស្រុកត្បូង | វេទិការសារធារណៈ | 6 លើក | 330 នាក់ | 184 នាក់ |
| | | មន្ទីរអប់រំយុវជន និងកីឡា បានផ្សព្វផ្សាយស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងចំណាក់ស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្សដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស នៅសាលាហ៊ុន សែនតំបែរ វិទ្យាល័យ ហ៊ុន សែនព្រែកអាជី អនុវិទ្យាល័យ | មន្ទីរអប់រំយុវជន និងកីឡា | 7 លើក | 1,391 នាក់ | 766 នាក់ |
| 4 | កំពត | បានសហការជាមួយមន្ទីកិច្ចការនារី មន្ទីរអង្គភាពជំនាញពាក់ពន្ធ័ ក្រុមការងារទាំង ៦ ធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើស្រ្តី និងកុមារ ការធ្វើការចំណាកស្រុកដោយសុវត្ថិភាព នៅតាមស្រុក( ស្រុកឈូក ក្រុងកំពត )តាមវេទិការសាធារណ | មន្ទីកិច្ចការនារី | 6 លើក | 2,254 នាក់ | 892 នាក់ |
| 5 | តាកែវ | បានធ្វើការផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅស្រុកសំរោង និងស្រុកត្រាំកក់ ។ | មន្ទីកិច្ចការនារី | 3 លើក | 75 នាក់ | 50 នាក់ |
| 6 | ពោធិ៍សាត់ | បានធ្វើការផ្សាព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមភូមិឃុំមានសុវត្ថិភាព ក្រុងពោធិ៍សាត ស្រុកក្រគរ កណ្តៀង ភ្នំក្រវាញ បាកាន វាលវែង | លេខាធិការដ្ឋាន គ.ខ.ប.ជ | 170 លើក | 29,097 នាក់ | 16,146 នាក់ |
| | | បានបញ្ជ្រាបវេទិកាសាធារណៈ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាម ភូមិ-ឃុំមានសុវត្ថិភាព ស្រុកបាកាន ស្រុកក្រគរ | | 18 លើក | 1,115 នាក់ | 732 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | កំពង់ឆ្នាំង | បានអប់រំផ្សព្វផ្សាយតាមវេទិកាសហគមន៍យេនឌ័រ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈភូមិ/ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ អាជ្ញាធរ អង្គការ សង្គមស៊ីវិល កងកំលាំងមានសមត្ថកិច្ច និងប្រជាពលរដ្ឋ | លេខាធិការដ្ឋាន មន្ទីរសង្គមកិច្ច | 4 លើក | 240 នាក់ | 170 នាក់ |
| | | មន្ទីរសង្គមកិច្ចការនារីបានសហការជាមួយអង្គការទស្សនៈពិភពលោកនិងអង្គការកម្ពុជាត្រាស្តធ្វើការផ្សព្វផ្សាយស្តីពីការចំណាក់ស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្សដល់ប្រជាពលរដ្ឋ | មន្ទីរកិច្ចការនារីខេត្ត និង អង្គការ | 6 លើក | 240 នាក់ | 140 នាក់ |
| 8 | កែប | បានបញ្ជ្រាបការទប់ស្កាត់ការធ្វើចំណាក់ស្រុកដោយខុសច្បាប់ជូនដល់ប្រជាពលរដ្ឋ និងផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈវេទិកាផ្សព្វផ្សាយស្តីពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 705 នាក់ | 372 នាក់ |
| 9 | ព្រះវិហារ | បានផ្សព្វផ្សាយច្បាប់តាមរយៈវេទិការសាធារណៈ ស្តីពការលើកកម្ពស់ការយល់ដឹង អំពច្បាប់ប្រឆាំងអំពើអាស ការជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បញ្ជ្រាបដល់ភូមិ-ឃុំមានសុវត្ថិភាព ដែលមានមន្ត្រីរាជការ និងប្រជាពលរដ្ឋចូលរួម ។ | ស្នងការដ្ឋាននគរបាលខេត្ត | 30 លើក | 3,646 នាក់ | 2,262 នាក់ |
| 10 | បាត់ដំបង | បានចុះ អប់រំផ្សព្វផ្សាយ និងធ្វើវេទិកាសាធារណៈស្តីពី ការអនុវត្តន៍គោលនយោបាយភូមិឃុំ/មានសុវត្ថិភាព ដល់កងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅតាមស្រុក( ក្រុង បាត់ដំបង បវេល ថ្មគោល សង្កែ រតនមណ្ឌល រុក្ខគីរី ម៉ោងឫស្សី ឯកភ្នំ បាណន ភ្នំព្រឹក កំរៀង សំឡូត សំពៅលូន គាស់ក្រឡ ) | គណៈកម្មាធិការ គ.ខ.ប.ជ | 193 លើក | 24,603 នាក់ | 12,059 នាក់ |
| 11 | ព្រះសីហនុ | ក្រុមការងារ ( គ ខ ប ជ ) បានសហការជាមួយអាជ្ញាធរក្រុង /ស្រុកតាមរយៈការផ្សព្វផ្សាយ គោលនយោបាយភូមិឃុំ មានសុវត្ថិភាព និងអង្គការជាដៃគូរ ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ការចំណាក់ស្រុកខុសច្បាប់ | គណៈកម្មាធិការ គ.ខ.ប.ជ | 6 លើក | 263 នាក់ | 66 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិការសារធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាជន | | 13 លើក | 449 នាក់ | 173 នាក់ |

សកម្មភាពសរុបចំនួន: 843 លើក

មនុស្សសរុបចំនួន: 103,665 នាក់

ស្រីសរុបចំនួន: 52,447 នាក់

# ឧបសម្ព័ន្ធទី២

## ការទារបង្ការទប់ស្កាត់

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | កន្លែង/គោលដៅ | មនុស្សសរុប | ស្ត្រី |
|---|---|---|---|---|---|---|
| 1 | កណ្តាល | ក្រុមការងារ ស្រុក ក្រុង បានធ្វើការប្រជុំជាមួយមន្ត្រីពាក់ពន្ធ័ ក្រុមប្រឹក្សាភូមិ ឃុំ ស្តីពីបញ្ហាជួញដូរមនុស្ស និងការចំណាក់ស្រុក ការលប់បំបាត់ពលកម្ម កុមារ | - មន្ត្រីក្រុង<br>- ក្រុមប្រឹក្សាស្រុក ឃុំ ភូមិ | 1 លើក | 120 នាក់ | 85 នាក់ |
| 2 | សៀមរាប | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលខេត្ត ចុះល្បាតពេលយប់ តាមផ្សាររាត្រី តាមមាត់ស្ទឹងសៀមរាប និងតាមសួនច្បារមុខមហាសណ្ឋាគារអង្គរជាប្រចាំ | ស្នងការនគរបាលខេត្ត | 4 លើក | | |
| 3 | ស្ទឹងត្រែង | ស្នងការដ្ឋាននគរបាលខេត្ត បានទប់ស្កាត់ប្រជាពលរដ្ឋមកពីខេត្តពោធិ៍សាត់បំរុងឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសឡាវ(ធ្វើការនៅក្រុមហ៊ុន វ៉ារីអគ្គីសនី) អោយត្រឡប់ទៅផ្ទះវិញ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 10 នាក់ | 0 នាក់ |
| 4 | បន្ទាយមានជ័យ | ការិយាល័យប្រឆាំងការជួញដូរមនុស្សបានធ្វើការបង្រាបជាក់ស្តែង មានទីតាំងម៉ាស្សា កោស ជប់ ដែលប្រព្រឹត្តសញ្ញាកម្ម មានទីតាំងស្ថិតនៅក្នុងភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ហើយ បានជួយស្ត្រីរងគ្រោះបំរើសេវាផ្លូវភេទ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 0 នាក់ | 3 នាក់ |
| 5 | ពោធិ៍សាត់ | ចុះត្រួតពិនិត្យ តាមដានមុខសញ្ញា និងមានវិធានការទប់ស្កាត់បទល្មើសដែលបានកើតឡើង មានៈ (សណ្ឋាគារ. ផ្ទះសំណាក់. ខារ៉ាអូខេ .ម៉ាស្សា .ភោជនីយដ្ឋាន .អាហារដ្ឋាន .ហាងកាហ្វេ និងក្លឹបកំសាន្ត ។ | ស្នងការដ្ឋាននគរបាលខេត្ត | 179 កន្លែង | 833 នាក់ | 591 នាក់ |
| ៦ | ឧត្តរមានជ័យ | បានស្រង់ស្ថិតិតាមគោលដៅ( សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ម៉ាស្សា ភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ ក្លឹបកម្សាន្ត ) និងបានណែនាំពន្យល់ច្បាប់ ស្តីពីអំពើជួញដូរមនុស្ស ដល់ម្ចាស់អាជីវកម្មទាំងនោះ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 120 នាក់ | 15 នាក់ |
| 7 | ក្រចេះ | កំលាំងសមត្ថកិច្ចនគរបាលខេត្ត បានចុះត្រួតពិនិត្យតាមសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ហាងម៉ាស្សា ក្លឹបខារ៉ាអូខេ និងនារីផ្សព្វផ្សាយស្រាបៀរ ដែលមានចំនួន២០៦៥បន្ទប់ | ស្នងការនគរបាលខេត្ត | 463 លើក | 768 នាក់ | 486 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | ព្រៃវែង | កំលាំងសមត្ថកិច្ចនគរបាលខេត្ត បានចុះល្បាតត្រួតពិនិត្យតាមគោលដៅហាងកាហ្វេ មាន បញ្ចាំងវីដេអូអាសអាភាស និងហាងខារ៉ាអូខេ ដែលប្រព្រឹត្តអំពើខុសច្បាប់ ហើយបានហាមឃាត់មេខ្យល់ និងបានធ្វើកិច្ចសន្យាថាមិនមានអំពើបែបនេះទៀតទេ និងបានធ្វើការស្រាវ ជ្រាវរាល់អំពើជួញដូរមនុស្ស ការធ្វើះអាជីវកម្មផ្លូវភេទ ។ | ស្នងការនគរបាលខេត្ត | 5 លើក | 12 នាក់ | 6 នាក់ |
| 9 | ស្វាយរៀង | បន្តផ្សព្វផ្សាយអំពីសេចក្តីណែនាំលេខ០០៥ របស់អគ្គស្នងការនគរបាលជាតិ ដល់ម្ចាស់អាជីវកម្មសង្ស័យពាក់ព័ន្ធបទល្មើសផ្លូវភេទ ទៅដល់បណ្តាអាជីវកម្ម ខារ៉ាអូខេ ផ្ទះសំណាក់ ផ្ទះជួល ម៉ាស្សាកោសជប់ ផ្ទះលក់ការហ្វេ និងជួលលក់វីស៊ីឌី ធ្វើនៅក្រុងស្វាយរៀង និងក្រុងបាវិត ។ | ស្នងការដ្ឋាននគរបាលខេត្ត | 15 លើក | 448 នាក់ | 168 នាក់ |

សកម្មភាពសរុប: 681 លើក

មនុស្សសរុបចំនួន: 2,311 នាក់

ស្រីសរុបចំនួន: 1,354 នាក់

## ឧបសម្ព័ន្ធទី៣

## ការងារការពារស្តារនីតិសម្បទា ជនរងគ្រោះ

| ល.រ | អង្គភាព | សកម្មភាព | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|
| 1 | រាជធានីភ្នំពេញ | ស្រុក/ក្រុងបានធ្វើការសហការជាមួយអង្គការមេត្រីអន្តរជាតិទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើការសួរសុខទុក្ខ ។ | 64 នាក់ | 64 នាក់ |
| 2 | ស្វាយរៀង | បានទទួលជនរងគ្រោះដោយការជួញដូរមនុស្សខុសច្បាប់យកទៅរៀបការស្វាមីនៅប្រទេសចិន ឆ្លងកាត់តាមប្រទេសវៀតណាម បានចំនួន១លើក មានចំនួន ៣នាក់ នៅភូមិសំរោង ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវចំនួន០១នាក់ រស់នៅភូមិថ្មី ឃុំ សន្ទុង ស្រុមខ្សាច់កណ្តាល ខេត្តកណ្តាលចំនួន០១នាក់ រស់នៅភូមិ បាត់លាស្នាប់ ឃុំ ពាមជីលាំងស្រុក ត្បូងឃ្មុំចំនួន០១នាក់ អ្នកទាំង០៣ខាងលើនេះ ត្រូវបានមេខ្យល់នាំយកទៅដល់ព្រំដែនប្រទេសវៀតណាម និងព្រំដែនចិន។ | 3 នាក់ | 3 នាក់ |
| | | បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ចំនួនពីរលើក ដែលទៅលក់ឆ្នោតនិងសុំទានតាមច្រកទ្វារសំរោង បានធ្វើកិច្ចសន្យាអោយត្រឡប់ទៅផ្ទះវិញ មាន១៩គ្រួសារមនុស្សរួមមាន ៤៦នាក់ ចាស់ ១៧ នាក់ ស្រី ៣៩នាក់ កុមារ ២៩នាក់ កុមារី ២២នាក់ (តាមច្រកទ្វារអន្តរជាតិព្រៃវល្លិ៍) និងបានអប់រំណែនាំស្តីពីការធ្វើចំណាក់ស្រុកដោយខុសច្បាប់។ | 46 នាក់ | 39 នាក់ |
| 3 | សៀមរាប | ការិយាល័យការពារផ្លូវច្បាប់នៃមន្ទីរកិច្ចការនារីខេត្ត បានទទួល និងរៀបចំបែបបទបញ្ជូនជនរងគ្រោះដោយការចំណាកស្រុក ទៅរៀនជំនាញផ្នែក កាត់ដេរ អ៊ុតសក់ និងជួសជុលម៉ូតូនៅមណ្ឌលអង្គការអាហ្វេស៊ីបកម្ពុជា ។ | 4 នាក់ | 2 នាក់ |
| 4 | បន្ទាយមានជ័យ | បុគ្គលិកមន្ទីរសង្គមកិច្ចបានចុះសម្ភាសជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ក្នុងចំណោមនីទេសជនដែលអាជ្ញាធរ ថៃបញ្ជូនមក ។ | 6 នាក់ | 2 នាក់ |
| 5 | ឧត្តរមានជ័យ | មន្ទីរសង្គមកិច្ចបានសហការជាមួយអង្គការជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធទទួលជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានធ្វើសមាហរណកម្មជួបជុំគ្រួសារ សាច់ញាតិនៅក្នុងសហគមវិញ ។ | 25 នាក់ | 15 នាក់ |
| 6 | កំពង់ឆ្នាំង | មន្ទីរសង្គមកិច្ចបានជួយអន្តរាគមន៍ពលការនីរងគ្រោះដោយអំពើជួញដូរទៅធ្វើការជាមេផ្ទះនៅប្រទេសម៉ាឡេស៊ី មាននារី១នាក់ និងកុមារ៉ាម្នាក់ចេញបាត់ពីផ្ទះ ត្រូវបានធ្វើសមាហរណកម្មជួបជុំគ្រួសារ សាច់ញាតិវិញ ។ | 5 នាក់ | 1 នាក់ |

មនុស្សសរុបចំនួន: 153 នាក់

ស្រីសរុបចំនួន: 126 នាក់

# តារាងឧបសម្ព័ន្ធទី៧
# ការងារដឹកនាំសម្របសម្រួល

| លរ. | អង្គភាព | សកម្មភាព | លើក | អ្នកពាក់ព័ន្ធ |
|---|---|---|---|---|
| | | -ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ មានបើកកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីការបែងចែកភារកិច្ចសម្រាប់សន្និបាត បូកសរុបការងារប្រចាំឆ្នាំ ២០១៥ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ដែលដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ទោ យ៉ែម ច័ន្ទណារុំ** អគ្គលេខាធិការរង គ.ជ.ប.ជ ។<br>-រៀបចំ និងបញ្ជូនលិខិតអញ្ជើញដល់រាជធានី-ខេត្ត ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការជាតិ-អន្តរជាតនានា ដើម្បីចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ របស់ គ.ជ.ប.ជ និងពិធីប្រកាសដាក់ឲ្យប្រើប្រាស់គោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។<br>-ចូលរួមបូកសរុបរបាយការណ៍ថ្នាក់ជាតិ ពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្នាំ២០១៥ ។ | | |
| ១ | គណៈកម្មាធិការជាតិ គជ.ប.ជ. | -លិខិតរបស់ គ (ច្បាប់១៤)៖ លិខិតចេញ គ.ជ.ប.ជលិខិតចូល(១០ច្បាប់)<br>-លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លិខិតចេញ(០៩ច្បាប់) លិខិតចូល(១៥ច្បាប់)<br>-ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានសកម្មភាពការងារប្រចាំថ្ងៃរបស់មន្ត្រី ធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងខែរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ -ប្រមូលរបាយការណ៍ខែមករា ឆ្នាំ២០១៥ តាមបណ្តាអន្តរក្រសួង និងរាជធានី-ខេត្ត<br>-បញ្ចប់របាយការណ៍ខែមករា ឆ្នាំ២០១៥ របស់ គជ.ប.ជ.<br>-បញ្ចប់ការបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ គ.ជ.ប.ជ បន្តបង្កើតទម្រង់បញ្ចេញបញ្ចូលឃ្លាំងសម្រាប់ប្រើប្រាស់នៅ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តរក្សាទុករូបភាព និងសកម្មភាពថ្នាក់ជាតិ និងក្រោមជាតិចូលក្នុងបណ្ណា សារ Wiki បន្តដំណើរការបង្កើត Database បន្តគ្រប់គ្រងទំព័រ facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ស្រាវជ្រាវព័ត៌មានពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន និង comment ផ្សេងៗពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្សលើទំព័រ facebook ប្រមូលរបាយការណ៍តាមបណ្តារាជធានីខេត្ត/ តាមប្រព័ន្ធ Telegram និង Gmail ។ | 15 លើក | លេខាធិការដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | -ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ បានអមដំណើរលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមពីធីផ្សព្វផ្សាយគោលនយោបាយអប់រំកំណែទម្រង់វិស័យអប់រំ និងគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា នៅវិទ្យាល័យព្រះបាទសុរាម្រឹត ក្រុងកំពង់ឆ្នាំង និងនៅវិទ្យាល័យសហមុនី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។<br>-ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ បានសហការសម្របសម្រួល ប្រមូលផែនការសកម្មភាពបង្ការទប់ស្កាត់ របស់អន្តរក្រសួងស្ថាប័ន ដែលដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ។ បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាព ការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី/ខេត្ត តាមរយៈ Telegram ។ | 4 លើក | ក្រុមចំនួយកិច្ចការបង្ការទប់ស្កាត់ |
| | | -បន្តរៀបចំធ្វើរបាយការណ៍ចងក្រងជាសៀវភៅ ដែលក្រុមការងារជំនួយកិច្ចការការពារជនរងគ្រោះបានចុះ បណ្តុះបណ្តាលផ្សព្វផ្សាយតាមបណ្តាខេត្ត និងផែនការអនុវត្តបន្ត បន្តតាមដានចំនួនពលករ និងជនរងគ្រោះ ដែលបញ្ជូនមកពី ប្រទេសក្រៅ បានរៀងតារាងទិន្នន័យជនរងគ្រោះ ។បានចុះផ្សព្វផ្សាយ គោលនយោបាយ របស់ក្រសួងអប់រំទៅលើ មន្ទីរអប់រំ និងបណ្តាសាលារៀនទាំងអស់ក្នុង ខេត្តកំពង់ឆ្នាំង ។<br>-បានជួបប្រជុំក្រុមធ្វើការពិភាក្សាលើផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៦ និងកំណត់ពេលវេលាសម្រាប់ការអនុវត្ត ។ | 6 លើក | ក្រុមចំនួយកិច្ចការការពារជនរងគ្រោះ |
| | | -បានទំនាក់ទំនងការងារពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ជាមួយខេត្ត កោះកុង ព្រះសីហនុ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ។ ព្រាងកសាងផែនការសម្រាប់ត្រីមាស និងឆ្នាំ២០១៦ គ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌនៃការជួញដូរមនុស្ស ។ មន្ត្រីតុលាការ ព្រះរាជអាជ្ញា និងចៅក្រមមាសសមត្ថភាព ប្រើប្រាស់ជនរងគ្រោះជាសាក្សី ក្នុងដំណើរការរឿងក្តី សម្រង់ទិន្នន័យពីក្រុមអនុវត្តច្បាប់ឆ្នាំ២០១៥ ។ សម្រង់ទិន្នន័យពីក្រុម អនុវត្តច្បាប់ខែមករា ឆ្នាំ២០១៦ បន្តធ្វើផែនការសកម្មភាពជាពង្រាងជាមួយអង្គការ GVC ។ | 5 លើក | ក្រុមចំនួយកិច្ចការការងារអនុវត្តន៍ច្បាប់ |
| | | -ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បានទំនាក់ទំនងទៅកញ្ញាវិច្ចិកា ប្អូនស្រីរបស់ សឿន រដ្ឋា ដើម្បីស៊ើបបញ្ជាក់ ឲ្យបានច្បាស់ពីករណីនារីឈ្មោះ ស៊ាម សុខណែម ដែលត្រូវត្រឡប់មកកម្ពុជាវិញថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៦ តែបែរជាមិនបាន មកតាមការសន្យា ។ ជាលទ្ធផលនាង ស៊ាម សុខណែម ត្រូវបានខាងភ្នាក់ងារ នៅម៉ាឡេស៊ី បញ្ជូនត្រឡប់មក កម្ពុជាវិញតាមកាលវេលាកំណត់ដូចមានចុះក្នុងសំបុត្រយន្តហោះហើយ តែដោយសារនាងធ្វេសប្រហែសខ្លួនឯង check-in មិនទាន់ទើបត្រូវយន្តហោះចេញចោល ខាងភ្នាក់ងារក៏បាននាំនាងទៅរស់នៅជាមួយបណ្តោះអាសន្នសិន ហើយនឹង បញ្ជូននាងមកសារជាថ្មីម្តងទៀតនៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៦ ខាងមុខនេះ ។ | | ក្រុមចំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | | បានស្រាវជ្រាវ និងប្រមូលព័ត៌មានតាមរយៈគេឡេក្រាម គេហទំព័រ និងសារព័ត៌មានផ្សេងៗពាក់ព័ន្ធនឹង ការអន្តរាគមន៍ជួយសង្គ្រោះពលករពលការនីកម្ពុជា- ហើយទទួលបានព័ត៌មានដូចខាងក្រោម៖<br>• ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងក្វាងចូវ ប្រទេសចិន បានអន្តរាគមន៍ជួយស្ត្រីខ្មែររងគ្រោះចំនួន០២នាក់ ដែលប្តីធ្វើបាប ស្ត្រីរងគ្រោះទាំងពីរនាក់បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ តាមជើងយន្តហោះ CZ6059 ។<br>• ស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃបានសហការជាមួយអាជ្ញាធរថៃ បញ្ជូនសពពលករខ្មែរ០១នាក់ ឈ្មោះ ម៉ម ឌិត អាយុ២៥ឆ្នាំ ដែលបានស្លាប់ក្នុងជម្លោះផឹកស៊ីជាមួយពលករខ្មែរដូចគ្នានៅក្នុងខេត្ត សមុទ្រប្រាកាន ត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី២៨ មករា ២០១៦។<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០១នាក់ នៅប្រទេសចិន ឈ្មោះ វ៉ែក សុភ័ក្ត អាយុ២៦ឆ្នាំ ដែលត្រូវបានមេខ្យល់បោកប្រាស់នាំយកទៅរៀបការជាមួយបុរសចិនតាំងពីឆ្នាំ២០១២ ។<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០២នាក់ នៅប្រទេសម៉ាឡេស៊ី<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០៣នាក់ នៅប្រទេសវៀតណាមមេខ្យល់បោក ប្រាស់នាំយកទៅរៀបការនៅប្រទេសចិន ដោយឆ្លងកាត់តាមព្រំប្រទល់ប្រទេសវៀតខាងជើងនិង វៀតណាមខាងត្បូង) បានជួយសង្គ្រោះជនជាតិខ្មែរ ០២នាក់ នៅប្រទេសថៃ ដែលបានទៅធ្វើការនៅថៃពុំមានឯកសារស្របច្បាប់ ។<br>• ពលករខ្មែរ ០១នាក់ ឈ្មោះ ម៉ៃ អាយុ២៥ឆ្នាំ ត្រូវបានគេសម្លាប់ ហើយយកសពទៅកប់ចោលនៅក្នុងព្រៃរបោះក្បែរទីតាំងសំណង់មួយកន្លែងជិតប្រព័ន្ធធារាសាស្ត្រទី៣ ត្រើយខាងកើតអូរ ស្ថិតក្នុងភូមិ១ ឃុំបឹងយីថុ ខេត្តប៉ាធុមថានី ប្រទេសថៃ ។<br>• ការអន្តរាគមន៍ជួយសង្គ្រោះស្ត្រីរងគ្រោះ ដែលចាញ់បោកមេខ្យល់យកទៅរៀបការនៅប្រទេសចិនចំនួន៤នាក់ និងពលករកម្ពុជា១នាក់ ដែលបានទទួលរងនូវការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅប្រទេសចិនដែរ ហើយត្រូវបាន ស្ថានកុងស៊ុលកម្ពុជានៅក្វាងចូវ សហការជាមួយអាជ្ញាធរចិនជួយសង្គ្រោះឲ្យត្រឡប់មកកម្ពុជាវិញ ។<br>• អគ្គរាជទូតកម្ពុជានៅប្រទេសជប៉ុន បានជួយអន្តរាគមន៍ដោះស្រាយបញ្ហា ៤យ៉ាងពាក់ព័ន្ធការងារមួយ ចំនួនដល់កម្មសិក្សាការីកម្ពុជាចំនួន៣៧នាក់ មានដូចជា៖ បញ្ហាស្នើគណនាប្រាក់បៀវត្សន៍ឲ្យបានត្រឹមត្រូវមិនលម្អៀង សូមតម្លើងប្រាក់ថែមម៉ោង បញ្ហាឈប់សម្រាកនៅថ្ងៃអាទិត្យ និងម៉ោងធ្វើការពីម៉ោង៨ព្រឹកដល់ម៉ោង៥ល្ងាច ហើយចង់ថែមម៉ោងសុំត្រឹមម៉ោង១០យប់ នៅរោងចក្រអ៊ុតខោអាវ ៣ កន្លែង ។<br>• គេហទំព័រវិទ្យុអាស៊ីសេរីបានចុះផ្សាយ(តែមិនមានភាពច្បាស់លាស់)ស្តីពីកម្មការនី០១នាក់ ធ្វើការនៅប្រទេស អារ៉ា | 10 លើក | ក្រុមចំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | | បីសាអ៊ូឌីត ទាមទារឲ្យក្រុមហ៊ុន ដែលបញ្ជូននាងទៅ នាំនាងត្រឡប់មកកម្ពុជាវិញ ដោយសារបញ្ហាសុខភាព ទទួលរងការធ្វើបាបពី ម្ចាស់ផ្ទះ និងទទួលអាហារនិងពេលសម្រាកមិនបានគ្រប់គ្រាន់ ។<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០២នាក់ នៅប្រទេសម៉ាឡេស៊ី ។<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០៣នាក់ នៅប្រទេសវៀតណាម ត្រូវបានមេខ្យល់បោក ប្រាស់នាំយកទៅរៀបការនៅប្រទេសចិន ដោយឆ្លងកាត់តាមព្រំប្រទល់ប្រទេសវៀតណាម (វៀតណាមខាងត្បូង និងខាងត្បូង) ។<br>• បានជួយសង្គ្រោះជនជាតិខ្មែរ ០២នាក់ នៅប្រទេសថៃ ដែលបានទៅធ្វើការនៅថៃពុំមានឯកសារស្របច្បាប់ ។<br>• ពលករខ្មែរ ០១នាក់ ឈ្មោះ ម៉ៃ អាយុ២៥ឆ្នាំ ត្រូវបានគេសម្លាប់ ហើយយកសពទៅកប់ចោលនៅក្នុង ព្រៃរបោះក្បែរទីតាំងសំណង់មួយកន្លែងជិតប្រព័ន្ធជារាសាស្ត្រទី៣ ត្រើយខាងកើតអូរ ស្ថិតក្នុងភូមិ១ ឃុំបឹងយីថុ ខេត្តប៉ាធុមថានី ប្រទេសថៃ ។<br>• ការអន្តរាគមន៍ជួយសង្គ្រោះស្ត្រីរងគ្រោះដែលចាញ់បោកមេខ្យល់យកទៅរៀបការនៅប្រទេសចិនចំនួន ៤នាក់ និងពលករកម្ពុជា១នាក់ដែលបានទទួលរងនូវការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅប្រទេសចិនដែរ ហើយត្រូវបានស្ថានកុងស៊ុលកម្ពុជានៅក្វាងចូវ សហការជាមួយអាជ្ញាធរចិនជួយសង្គ្រោះឲ្យត្រឡប់មក កម្ពុជាវិញ ។<br>• អគ្គរាជទូតកម្ពុជានៅប្រទេសជប៉ុន បានជួយអន្តរាគមន៍ដោះស្រាយបញ្ហា ៤យ៉ាងពាក់ព័ន្ធការងារមួយ ចំនួនដល់កម្មសិក្សាការីកម្ពុជាចំនួន ៣៧នាក់ មានដូចជា៖ បញ្ហាស្នើគណនាប្រាក់បៀវត្សន៍ឲ្យបាន ត្រឹមត្រូវមិនលម្អៀង សូមតម្លើងប្រាក់ថែមម៉ោង បញ្ហាឈប់សម្រាកនៅថ្ងៃអាទិត្យ និងម៉ោងធ្វើការពី ម៉ោង៨ព្រឹកដល់ម៉ោង៥ល្ងាច ហើយចង់ថែមម៉ោងសុំត្រឹមម៉ោង១០យប់ នៅរោងចក្រអ៊ុតខោអាវ ៣ កន្លែង ។<br>គេហទំព័រវិទ្យុអាស៊ីសេរីបានចុះផ្សាយ(តែមិនមានភាពច្បាស់លាស់) ស្តីពីកម្មការនី ០១នាក់ទៅធ្វើការនៅប្រទេស អារ៉ាប៊ីសាអ៊ូឌីត ទាមទារឲ្យក្រុមហ៊ុន ដែលបញ្ជូននាងទៅ នាំនាងត្រឡប់មកកម្ពុជាវិញ ដោយសារបញ្ហាសុខភាព ទទួលរងការធ្វើបាបពី ម្ចាស់ផ្ទះ និងទទួលអាហារនិងពេលសម្រាកមិនបានគ្រប់គ្រាន់ ។<br>-បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញ (ពីថ្ងៃ ទី២០ ខែមករា ដល់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦) សរុបចំនួន ៤.១៥៣នាក់(ស្រី ១.៣៦៤នាក់ កុមារ ៣៤១នាក់) ក្នុងនោះ៖<br>• តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន ៣.៦៨៣នាក់ (ស្រី ១.២០៨នាក់ កុមារ ២៩២នាក់)<br>• តាមច្រកសំពៅលូន ខេត្តបាត់ដំបង ចំនួន ៤៧០នាក់ (ស្រី ១៥៦នាក់ កុមារ ៤៩នាក់) ។ | | ក្រុមចំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| ២ | កោះកុង | ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការជាតិ គ.ខ.ប.ជ និងលោកជំទាវអភិបាលរងខេត្ត លោកប្រធានមន្ទីរសង្គមកិច្ច និងស្នងការរងនគរបាលខេត្ត បានអញ្ជើញចូលរួមសន្និបាតបូក សរុបការងារ របស់ គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៥ ទិសដៅឆ្នាំ ២០១៦ នៅក្រ សួងមហាផ្ទៃ ។ | 1លើក | គណៈកម្មាធិកា គ.ខ.ប.ជ ខេត្ត |
| | ប៉ៃលិន | -ឯកឧត្តម កើត សុជា អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការជាតិ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ឆ្នាំ ២០១៥ និង លើកទិសដៅអនុវត្តបន្តឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួន៧៥នាក់ ស្រីចំនួន២០នាក់ ។<br>-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិកា គ ជ.ប.ខ.លោកជំទាវអភិបាលរងខេត្ត លោកប្រធានមន្ទីរសង្គមកិច្ច និងស្នងការរងនគរបាលខេត្ត បានអញ្ជើញចូលរួមសន្និបាតបូកសរុបការងារ របស់គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្រសួងមហាផ្ទៃ ។ | 2លើក | គណៈកម្មាធិកា គ.ខ.ប.ជ ខេត្ត |
| | បន្ទាយមានជ័យ | អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការជាតិ គ.ខ.ប.ជ និងលោកជំទាវ អភិបាលរងខេត្ត លោកប្រធានមន្ទីរសង្គមកិច្ច និងស្នងការរងនគរបាលខេត្ត បានអញ្ជើញចូលរួមសន្និបាតបូក សរុបការងារ របស់គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៥ ទិសដៅឆ្នាំ ២០១៦ នៅក្រសួងមហាផ្ទៃ ។ | 1 លើក | គណៈកម្មាធិកា គ.ខ.ប.ជ ខេត្ត |
| ៣ | កំពត | -គណៈកម្មាធិការ គ ខ ប ជ ខេត្ត បានប្រជុំលេខាធិការដ្ឋាននិងក្រុមការងារទាំង ៦ដើម្បីត្រួតពិនិត្រអនុវត្តន៍ការងារ បន្តនិរន្តភាព ក្នុងការដឹកនាំគ្រប់គ្រង និងជំរុញអោយក្រុមការងារខិតខំប្ដឹងប្រែងយកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងសភាពការណ៍បទល្មើស គ្រប់គ្រងមុខសញ្ញាទប់ស្កាត់រាល់បណ្ដាសកម្មភាពបទល្មើស និងការផ្សព្វផ្សាយ អប់រំដល់ស្រទាប់ មហាជន ឲ្យបានជ្រួតជ្រាបពីល្បិចកលរបស់ជនល្មើសធ្វើយ៉ាងណាអោយជៀសផុតពីការរងគ្រោះ ពីការជួញដូរមនុស្ស ។ | 1 លើក | គណៈកម្មាធិការ គ ខ ប ជ ខេត្ត |
| ៤ | កណ្ដាល | ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានធ្វើការប្រជុំជាមួយមន្ត្រីពាក់ព័ន្ធ ក្រុមប្រឹក្សាភូមិ ឃុំ ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក ការលុបបំបាត់ពលកម្មកុមារ បានចំនួន១លើក មានអ្នកចូលរួមចំនួន ១២០នាក់ ស្រីចំនួន ៤៥នាក់ ។ | 1 លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត |
| ៥ | សៀមរាប | -លោកជំទាវប្រធានលេខាធិការដ្ឋាន គ ជ.ប.ខ.បានដឹកនាំកិច្ចប្រជុំ ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ឆ្នាំ២០១៥ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួន១៧នាក់ ស្រីចំនួន១០នាក់ ។<br>-ឯកឧត្តម ឃឹម ប៊ុនសុង អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ និងលោកជទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញចូលរួមសន្និបាតបូកសរុបការងារ របស់គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំង | 2 លើក | គណៈកម្មាធិការ គ ខ ប ជ ខេត្ត |

| | | | | |
|---|---|---|---|---|
| | | អំពើជួញដូរមនុស្សនៅក្រសួងមហាផ្ទៃ ។ | | |
| | កំពង់ធំ | -ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមប្រជុំ ស្តីពីបែបបទ និងនិតិវិធីនៃការកំណត់ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាពរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅសាលប្រជុំ ក្រសួងមហាផ្ទៃ (អគារ៦) ។<br>-បានប្រជុំពិភាក្សាជាមួយ ឯកឧត្តម អគ្គរាជទូតអាមេរិក ស្តីអំពីវិស័យសុខាភិបាល និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម អុក សំអន អភិបាលខេត្ត នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ។ | 2 លើក | គណៈកម្មាធិការ គ ខ ប ជ ខេត្ត |
| ៦ | ក្រចេះ | ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានធ្វើការប្រជុំ ស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ សាលប្រជុំនៅសាលាខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន៨៥នាក់ ស្រីចំនួន១៨នាក់ ។ | 1 លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត |
| | ស្វាយរៀង | -គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយអង្គការ NGOs ចូលរួមប្រជុំពិភាក្សាការងារប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងខេត្ត ដើម្បីជួយគាំទ្រ និងធ្វើអន្តរាគមន៍ទាន់ពេលវេលា ក្នុងករណីមានបទល្មើសកើតឡើង។<br>-បានប្រជុំពិភាក្សាជាមួយអង្គការឆាលហ្វានស្តីពីកិច្ចការពារកុមារ នៅការិយាល័យអង្គការហ្វាន ចំនួន០២ថ្ងៃ មានអ្នកចូលរួមសរុប០៨នាក់ ស្រីចំនួន០២នាក់ ។ | 1 លើក | គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត |

សកម្មភាពសរុបចំនួន ៥២លើក

## ឧបសម្ព័ន្ធទី៨

## លើកកម្ពស់សមត្ថភាព

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | តាកែវ | បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីជួរមុខលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ ខ ប ជ ) ខេត្ត និងដល់អ្នកទទួលបន្ទុកស្ត្រី និងកុមារថ្នាក់ភូមិនៅស្រុកអង្គរបូរី | គណៈកម្មាធិការ | 1 លើក | 26 នាក់ | 23 នាក់ |
| 2 | កំពង់ឆ្នាំង | រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ គ ខ ប ជស្តីពីការទប់ស្កាត់អំពីជួញដូរមនុស្ស | គណៈកម្មាធិការ | 1 លើក | | |
| 3 | ស្វាយរៀង | បានសហការជាមួយអង្គការឆាលហ្វានបើកវគ្គបណ្តុះបណ្តាល ស្តីពីការពារកុមារ និងទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ដល់(គកនគ)(គ អ ភ) | គណៈកម្មាធិការ | 2 លើក | 60 នាក់ | 28 នាក់ |

សកម្មភាពសរុបចំនួន: 3 លើក

មនុស្សសរុបចំនួន: 86 នាក់

ស្រីសរុបចំនួន: 51 នាក់

# តារាងផ្ទៀងផ្ទាត់របាយការណ៍ថ្នាក់ជាតិ ដែលបានទទួល និង មិនបានទទួល

## ចាប់ពីខែ មករា ដល់ខែ មិថុនា ឆ្នាំ ២០១៦

| ល.រ | អន្តរក្រសួង - ក្រុមការងារ -រាជធានី -ខេត្ត | មករា | កុម្ភៈ | មីនា | ត្រីមាសទី១ | មេសា | ឧសភា | មិថុនា | ត្រីមាសទី២ |
|---|---|---|---|---|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារបង្ការទប់ស្កាត់ | X | X | | | | | | |
| ២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន ក្រុមការងារការពារជនរងគ្រោះ | X | X | | | | | | |
| ៣ | អគ្គស្នងការនគរបាលជាតិ ក្រុមការងារអនុវត្តច្បាប់ | √ | √ | | | | | | |
| ៤ | ក្រសួងយុត្តិធម៌ ក្រុមការងារកិច្ចការយុត្តិធម៌ | X | X | | | | | | |
| ៥ | ក្រសួងការងារ និងបណ្តុះវិជ្ជាជីវៈ ក្រុមការងារទេសន្តរប្រវេសន៍ | X | X | | | | | | |
| ៦ | ក្រសួងកិច្ចការនារី ក្រុមការងារសហប្រតិបត្តិអន្តរជាតិ | X | X | | | | | | |
| ៧ | រាជធានីភ្នំពេញ | √ | √ | | | | | | |
| ៨ | កណ្តាល | √ | √ | | | | | | |
| ៩ | តាកែវ | √ | √ | | | | | | |
| ១០ | កំពត | √ | √ | | | | | | |
| ១១ | កែប | √ | √ | | | | | | |
| ១២ | ព្រះសីហនុ | √ | √ | | | | | | |
| ១៣ | កោះកុង | √ | √ | | | | | | |
| ១៤ | ពោធិ៍សាត់ | √ | √ | | | | | | |
| ១៥ | បាត់ដំបង | √ | √ | | | | | | |
| ១៦ | ប៉ៃលិន | √ | √ | | | | | | |
| ១៧ | បន្ទាយមានជ័យ | √ | √ | | | | | | |
| ១៨ | ឧត្តរមានជ័យ | √ | √ | | | | | | |
| ១៩ | សៀមរាប | X | √ | | | | | | |
| ២០ | កំពង់ធំ | √ | √ | | | | | | |
| ២១ | ព្រះវិហារ | √ | √ | | | | | | |
| ២២ | កំពង់ចាម | √ | √ | | | | | | |
| ២៣ | ត្បូងឃ្មុំ | √ | √ | | | | | | |
| ២៤ | ក្រចេះ | √ | √ | | | | | | |
| ២៥ | ស្ទឹងត្រែង | √ | √ | | | | | | |
| ២៦ | រតនគិរី | √ | √ | | | | | | |
| ២៧ | មណ្ឌលគិរី | √ | √ | | | | | | |
| ២៨ | ព្រៃវែង | X | √ | | | | | | |
| ២៩ | ស្វាយរៀង | √ | √ | | | | | | |
| ៣០ | កំពង់ស្ពឺ | X | X | | | | | | |
| ៣១ | កំពង់ឆ្នាំង | √ | X | | | | | | |
| អន្តរក្រសួង | បានផ្តល់របាយការណ៍ | ១ | ១ | | | | | | |
| | មិនបានផ្តល់របាយការណ៍ | ៥ | ៥ | | | | | | |
| រាជធានី ខេត្ត | បានផ្តល់របាយការណ៍ | ២២ | ២៣ | | | | | | |
| | មិនបានផ្តល់របាយការណ៍ | ៣ | ២ | | | | | | |
| ំណត់ ម្គាល់ | បានផ្តល់របាយការណ៍ | √ | √ | | | | | | |
| | មិនបានផ្តល់របាយការណ៍ | X | X | | | | | | |